00966698

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
19 / 12 / 2013
ម៉ោង (Time/Heure): 10:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E218/7/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣

**ជូនចំពោះ:** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ភាគីទាំងអស់ក្នុងសំណុំរឿង ០០២, អង្គភាពគាំពារជនរងគ្រោះ

**កម្មវត្ថុ:** សំណើសុំការបំភ្លឺអំពីគម្រោងសំណង

1. អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាចុងក្រោយស្តីពីសំណង (ឯកសារ E218/7/2, E218/7/4)។ អង្គជំនុំជម្រះក៏បានសម្រេចអនុញ្ញាតពន្យារពេលពីរសប្តាហ៍ដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់សារណាចុងក្រោយស្តីពីសំណង (ឯកសារ E218/7/5) សហមេធាវីនាំមុខ បានដាក់សារណាចុងក្រោយស្តីពីសំណងនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ជាភាសាបារាំង ដែលរួមមានទាំងឧបសម្ព័ន្ធចំនួន ១០ និងបានដាក់សំណៅជាភាសាខ្មែរនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ ( ឯកសារ E218/7/6, E218/7/6.1.1 និងឯកសារផ្សេងទៀត) ។

2. អង្គជំនុំជម្រះរំឭកថា អនុស្សរណៈរបស់អង្គជំនុំជម្រះលេខ E218/7/2 និង E218/7/4 តម្រូវឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលនៅក្នុងសំណើសុំសំណងរបស់ខ្លួននូវ៖ (១) ត្រូវ

បង្ហាញពីភស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបីណាមួយ។ (២) ត្រូវមានការធានាថាមានមូលនិធិពេញលេញ (៣) ត្រូវផ្តល់ព័ត៌មានបន្ថែមចាំបាច់នានា ដូចជាសេចក្តីពិពណ៌នាលម្អិត គម្រោងប្លង់ ឬរូបភាព និងផែនការថវិកាសម្រាប់សំណើសុំទាំងនោះផងដែរ (ឯកសារ E218/7/4, កថាខណ្ឌ៣)។

3. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីនាំមុខ មិនបានធានាទាំងស្រុងថាមានមូលនិធិសម្រាប់គម្រោងជាច្រើននោះទេ។ សហមេធាវីនាំមុខបញ្ជាក់ថា ខ្លួននឹងផ្តល់ព័ត៌មានបន្ថែមអំពីថវិកា (ឯកសារ E218/7/6, កថាខណ្ឌ ២៤១) ហើយជាការពិត បានដាក់ព័ត៌មានបន្ថែមទាក់ទិននឹងថវិកាបន្ថែមលើគម្រោងជាក់លាក់មួយចំនួន (ឯកសារ E218/7/6/1)។

4. អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា គម្រោងស្នើសុំជាក់លាក់មួយចំនួន ហាក់ដូចជាខ្វះសេចក្តីពិពណ៌នាលម្អិតគ្រប់គ្រាន់ ឬខ្វះការបង្ហាញពីភស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបីណាមួយ។ ឧទាហរណ៍ គម្រោងស្នើសុំស្តូបសម្រាប់រំឭកជាសាធារណៈ (ឯកសារ E218/7/6.1.2) បង្ហាញថា គម្រោងនេះនឹងមានការសាងសង់បូជនីយដ្ឋាន*ប្រហែល* ៥ កន្លែង ដែលបូជនីយដ្ឋានមួយកន្លែង ស្ថិតនៅរាជធានីភ្នំពេញ និងបានកំណត់ "ទីតាំងស៊ើបអង្កេតសំខាន់ៗ" ចំនួនប្រាំពីរ និងទីកន្លែងដែលបូជនីដ្ឋាននីមួយៗអាចតាំងនៅក្នុងខេត្តចំនួនប្រាំ។ ការជ្រើសរើសទីតាំងសម្រាប់បូជនីយដ្ឋាននីមួយៗ ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរួមរបស់សហគមន៍ ដែលមិនទាន់ត្រូវបានពិនិត្យបញ្ចប់នៅឡើយទេ។ សំណើសុំ ក៏បង្ហាញថា "បូជនីយដ្ឋាន គួរតែត្រូវបានសាងសង់នៅលើដីសាធារណៈ ប្រសិនបើមាន"។ មិនមានការបង្ហាញនូវទីតាំងជាក់លាក់ណាមួយដែលកំពុងពិចារណានោះទេ ហើយថាតើសាលារាជធានីភ្នំពេញបានអនុញ្ញាតដែរឬយ៉ាងណា។ ចំនួនថវិកាសរុបផ្សេងៗចំនួនពីរ ត្រូវបានលើកឡើង៖ ៤៥០.០០០ ដុល្លារអាមេរិក និង ៤៥៤.៩៥៤ ដុល្លារអាមេរិក។ មិនមានការរៀបរាប់ច្បាស់លាស់អំពីថវិកា និងមិនមានគម្រោងប្លង់ ឬគំរូបំព្រួញនោះទេ។ ចំពោះគម្រោងទី៣ ការសាងសង់បូជនីយដ្ឋានមួយនៅរាជធានីភ្នំពេញដើម្បីរំឭកដល់ជនរងគ្រោះនៃការជម្លៀសដោយបង្ខំ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានភស្តុតាងបង្ហាញអំពីការអនុញ្ញាតរបស់អាជ្ញាធររាជធានីភ្នំពេញ ឱ្យសាងសង់បូជនីយដ្ឋានលើទីតាំងដែលបានស្នើសុំ ដែលជាទ្រព្យសម្បត្តិសាធារណៈនោះទេ។

5. អង្គជំនុំជម្រះដាស់តឿនសហមេធាវីនាំមុខថា គម្រោងសំណើដែលមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ អាចនឹងមិនត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះនោះទេ។ ដើម្បីផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវឱកាសបំពេញលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងទទួលយកព័ត៌មានបន្ថែម ទាក់ទិននឹងគម្រោង

ស្នើសុំពីមុនណាមួយ រួមមានសេចក្តីពិពណ៌នាច្បាស់លាស់ ការព្រមព្រៀងរបស់ភាគីទីបី ឬការបង្ហាញអំពីថវិការហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។ ព័ត៌មានបន្ថែមនេះ ត្រូវរួមបញ្ចូលព័ត៌មានទាក់ទិននឹងគម្រោងស្នើសុំស្តួបសម្រាប់រំឭកជាសាធារណៈ ឬគម្រោងផ្សេងៗណាមួយ ដែលអាចខ្វះនូវលក្ខខណ្ឌតម្រូវដែលអង្គជំនុំជម្រះបានកំណត់ពីមុនមក។ ព័ត៌មានណាមួយដែលទទួលបានក្រោយកាលបរិច្ឆេទនេះ នឹងមិនត្រូវបានយកមកពិចារណានោះទេ។ បន្ថែមពីលើនេះ គម្រោងស្នើសុំបន្ថែម នឹងមិនត្រូវបានពិចារណាទៀតទេ លើកលែងតែគម្រោងស្នើសុំដែលបានដាក់នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។